# កំណត់ត្រាអំពីការចាក់វ៉ាក់សាំង COVID-19

## ការបង្ហាញភស្តុតាងអំពីស្ថានភាពចាក់វ៉ាក់សាំងនៅរដ្ឋ California



**រដ្ឋ California ត្រូវបានបើកឡើងវិញកាលពីថ្ងៃទី15 ខែមិថុនា ហើយការរឹតបន្តឹងផ្សេងៗ ត្រូវបានដកចេញ ដូចជាលក្ខខណ្ឌ កំណត់ចំនួនមនុស្ស និងការរក្សាគម្លាតសុវត្ថិភាព។ នៅតាមទីកន្លែងមួយចំនួន ពលរដ្ឋ California អាចនឹងត្រូវកំណត់ឱ្យបង្ហាញភស្តុតាងថាបានចាក់វ៉ាក់សាំងពេញលេញ។**

### តើខ្ញុំអាចបង្ហាញអំពីស្ថានភាពចាក់វ៉ាក់សាំងរបស់ខ្ញុំយ៉ាងដូចម្តេច?

នៅពេលទទួលបានវ៉ាក់សាំង COVID-19 អ្នកផ្តល់វ៉ាក់សាំងឱ្យអ្នកចេញជូនអ្នកនូវ *បណ្ណចាក់វ៉ាក់សាំងរបស់មជ្ឈមណ្ឌលការពារ និងទប់ស្កាត់ជំងឺ (CDC)* ។

បណ្ណនេះបង្ហាញឈ្មោះពេញ និងថ្ងៃខែឆ្នាំកំណើតរបស់អ្នក ប្រភេទវ៉ាក់សាំងដែលបានចាក់ លេខឡូត៍ កាលបរិច្ឆេទចាក់ដូសចុងក្រោយ និងទីតាំងចាក់វ៉ាក់សាំង។

វិធីបង្ហាញអំពីស្ថានភាពចាក់វ៉ាក់សាំងរបស់អ្នកមានដូចខាងក្រោម៖

- *បណ្ណចាក់វ៉ាក់សាំង COVID-19* ច្បាប់ដើម
- រូបថត *បណ្ណចាក់វ៉ាក់សាំង*របស់អ្នក
- ច្បាប់ចម្លង *បណ្ណចាក់វ៉ាក់សាំង*របស់អ្នក
- រូបថតបណ្ណចាក់វ៉ាក់សាំងរបស់អ្នករក្សាទុកនៅក្នុងទូរសព្ទដៃ ឬឧបករណ៍អេឡិចត្រូនិកផ្សេងទៀត
- រូបថតកំណត់ត្រាចាក់វ៉ាក់សាំងរបស់អ្នកពីអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។
- កំណត់ត្រាវ៉ាក់សាំង COVID-19 ឌីជីថល (DCVR)

ច្រក DCVR ទាញកំណត់ត្រាវ៉ាក់សាំង COVID-19 ពីប្រព័ន្ធចាក់វ៉ាក់សាំងរបស់រដ្ឋ California។ ប្រព័ន្ធនេះអាចឱ្យអ្នកចូល និងទាញយកឯកសារឌីជីថលនៃកំណត់ត្រាចាក់វ៉ាក់សាំង COVID-19 របស់អ្នក។




### សូមទាក់ទងអ្នកផ្តល់វ៉ាក់សាំងរបស់អ្នកដើម្បីស្នើសុំឯកសារកំណត់ត្រាចាក់វ៉ាក់សាំង COVID-19 របស់អ្នក

- សម្រាប់វ៉ាក់សាំងភាគច្រើនដែលបានចាក់នៅរដ្ឋCalifornia ទិន្នន័យវ៉ាក់សាំងមានបញ្ចូលនៅក្នុងប្រព័ន្ធព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់រដ្ឋ California (ហៅថា CA Immunization Registry2 ឬ CAIR2)។ ច្បាប់ចម្លងកំណត់ត្រារបស់អ្នកអាចស្នើសុំពី CAIR2 តាមរយៈទូរសព្ទ អ៊ីមែល ឬទម្រង់អនឡាញ (online form)។
- ប្រសិនបើអ្នកបានចាក់វ៉ាក់សាំងតាមរយៈអ្នកផ្តល់សេវាទាំសុខភាពរបស់អ្នក អ្នកអាចស្នើសុំច្បាប់ចម្លងកំណត់ត្រាចាក់វ៉ាក់សាំង COVID-19 របស់អ្នកពីអ្នកផ្តល់សេវា។
- ប្រសិនបើអ្នកបានទទួលវ៉ាក់សាំង COVID-19 នៅមូលដ្ឋានសហព័ន្ធ (ដូចជា នាយកដ្ឋានការពារ សេវាសុខភាព Indian ឬកិច្ចការអតីតយុទ្ធជន (Department of Defense, Indian Health Services, or Veterans Affairs) អ្នកនឹងត្រូវស្នើកំណត់ត្រាវ៉ាក់សាំងពីមូលដ្ឋាននោះដោយផ្ទាល់។ ព័ត៌មានមិនត្រូវបានដាក់ជូន ឬកត់ត្រានៅក្នុងបញ្ជីចាក់វ៉ាក់សាំង California Immunization Registry2 (CAIR2) ឡើយ។

### សំណួរ?

ប្រសិនបើអ្នកមានសំណួរណាមួយ សូមចូលមើលវេបសាយត៍ COVID-19VaccineRecord (ca.gov)

[1] បុគ្គលត្រូវបានចាត់ទុកថាបានចាក់វ៉ាក់សាំងពេញលេញរយៈពេល 2 សប្តាហ៍បន្ទាប់ពីចាក់ដូសទីពីរសម្រាប់វ៉ាក់សាំង 2 ដូស ដូចជា Pfizer ឬ Moderna ឬ 2 សប្តាហ៍បន្ទាប់ពីវ៉ាក់សាំងចាក់តែមួយដូស ដូចជាវ៉ាក់សាំង J & J។ វ៉ាក់សាំងត្រូវទទួលការអនុញ្ញាតពីរដ្ឋបាលចំណីអាហារ និងឱសថ (FDA) ឬអង្គការសុខភាពពិភពលោក (WHO)។

**ALAMEDA COUNTY HEALTH CARE SERVICES AGENCY**
**PUBLIC HEALTH DEPARTMENT**

Colleen Chawla – Agency Director
Kimi Watkins-Tartt – Director
Nicholas Moss, MD – Health Officer

**Contact**
Public Health Department:
(510) 267-8000 Main Line

COVID-19 Information:
(510) 268-2101

www.acphd.org